# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

## ព្រឹត្តិបត្រព័ត៌មាន

ប.ស.ស ឆ្នាំទី០៦ លេខ១១ ឆ្នាំ២០១៦




ធានាសន្តិសុខប្រាក់ចំណូល | រួមចំណែកកាត់បន្ថយភាពក្រីក្រ | លើកកម្ពស់ស្ថិរភាពសង្គម

## អ្នកមានជួយអ្នកក្រ
## អ្នកមានសុខភាពល្អជួយអ្នកឈឺ

**សេវាសង្គ្រោះបន្ទាន់**

**24h/7d**

**Hotline 1286**





មាតិកា
ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម......i

២- សន្និសីទ ស្តីពីពិធីអបអរសាទរ នៃការទទួលបានវិញ្ញាបនបត្រឆ្នើមក្នុងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសសឹង្ហបុរី......១

៣- ពិធីប្រជុំផ្សព្វផ្សាយអប់រំស្តីពីលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងអត្ថប្រយោជន៍របបសន្តិសុខសង្គម នៅខេត្តកណ្តាល .....៣

៤- កិច្ចប្រជុំ ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិតសាជាថ្មី ......៥

៥- ក្រុមការងារ ស.ផ.ក រៀបចំពិធីប្រជុំផ្សព្វផ្សាយ ស្តីពីការគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដល់កម្មករនិយោជិត និងអ្នកបើកបរ នៅខេត្តស្វាយរៀង ......៦

៧- កិច្ចប្រជុំផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត ស្តីពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន សុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត ......៧

៨- សិក្ខាសាលា ស្តីពីកំណែទម្រង់សន្តិសុខសង្គម ការផ្តល់តាវកាលិកសមស្រប សម្រាប់ជនគ្រប់រូប និងការសម្របទៅតាមនិន្នាការចម្បងនៃការងារ......៨

៩- បេឡាជាតិរបបសន្តិសុខសង្គម បានចាត់មន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្តល់សេវាបុននីតិសម្បទាសម្រាប់កម្មករនិយោជិតពិការ នៅប្រទេសថៃ......៩

១០- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារ......១០

១១- ក្រុមការងារ ស.ផ.ក បានចុះផ្សព្វផ្សាយអប់រំណែនាំ ដល់អ្នកបើកបរ និងកម្មករនិយោជិតតាមបណ្តាសហគ្រាស គ្រឹះស្ថាន ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ......១១

១២- កម្មករ-កម្មការិនីប្រមាណ ៤៦ នាក់ សន្លប់នៅក្រុមហ៊ុនសេរី (ខេមបូឌា) ខូអិលធីឌី ខេត្តកំពង់ស្ពឺ បណ្តាលមកពីក្រុមហ៊ុនបាញ់ថ្នាំសម្លាប់សត្វល្អិត ......១២

១៣- អនុក្រឹត្យ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ......១៣

១៤- អាហារដែលមានអត្ថប្រយោជន៍ដល់សុខភាព ......១៨

១៥- ក្រុមប្រចាំការ HOTLINE 24 ម៉ោង......១៩

១៦- ទស្សនអប់រំ ......២០

១៧- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត....២១

១៨- លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស......២៥

១៩- លិខិតអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ......៣០




## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លេខានិពន្ធ លោកស្រី សុខ សូរ្យស្មី

កញ្ញា យ៉េម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក ឃុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

លោក ឱម សុផានិត

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# សន្និសីទ ស្តីពីពិធីអបអរសាទរ នៃការទទួលបានវិញ្ញាបនបត្រឆ្នើមក្នុងការអនុវត្តរបប សន្តិសុខសង្គម ផ្នែកហានិភ័យការងារ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសសិង្ហបុរី

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅកម្ពុជា ជាអង្គភាពមួយទើបដំណើរការ ក្នុងរយៈពេលជិត ៧ ឆ្នាំប៉ុណ្ណោះ ប.ស.ស ទទួលបានសមាជិក និងមានសហគ្រាសជាច្រើនបានចុះបញ្ជិកាគួរឱ្យកត់សម្គាល់ ព្រមទាំងបានផ្តល់អត្ថប្រយោជន៍ ដល់សមាជិករបស់ខ្លួនមានលក្ខណៈពិសេសដាច់ដោយឡែក ដែលប្រទេសជាសមាជិក ASSA ទាំងអស់ពុំបានអនុវត្ត។

នេះជាមោទនភាពមួយរបស់អង្គភាព ប.ស.ស ដែលទទួលបានវិញ្ញាបនបត្រឆ្នើម ផ្នែកហានិភ័យការងារ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) ព្រមទាំងប្រទេសកម្ពុជាទាំងមូល ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។



បទបង្ហាញរបស់នាយក ប.ស.ស ស្តីពីការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

ទន្ទឹមនឹងនេះ នៅវេលាម៉ោង៣ រសៀល ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៥ នៅសាលប្រជុំទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ អមដោយឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ប្រធានអង្គភាព ក្រោមឱវាទក្រសួង និង



កិច្ចប្រជុំ ស្តីពីពិធីអបអរសាទរ នៃការទទួលបានវិញ្ញាបណ្ណបត្រឆ្នើមក្នុងការអនុវត្តន៍របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

សមាជិក ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម ក្នុងពិធីអបអរសាទរ នៃការទទួលបានវិញ្ញាបនបត្រឆ្នើម ក្នុងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA)។

កត្តាដែល ប.ស.ស ត្រូវបានចាត់ទុកជាអង្គភាពឆ្នើមផ្នែកនវានុវត្តន៍ (Innovation Excellence) មានដូចខាងក្រោម៖



ទិដ្ឋភាពរួមនៃកិច្ចប្រជុំ

១-ប.ស.សជាអង្គភាពមួយទើបបង្កើតថ្មីបើប្រៀបធៀបជាមួយអង្គភាពសន្តិសុខសង្គម នៃបណ្ដាប្រទេសក្នុងតំបន់មានវិសាលភាពគ្រប់ដណ្ដប់ទូទាំងប្រទេសក្នុងរយៈពេលខ្លី

២- ការចុះបញ្ជីសមាជិកតាមរយៈយន្តការ E-Form

៣- ការផ្ដល់តាវកាលិកព្យាបាលរហូតជាសះស្បើយ (មិនមានលក្ខខណ្ឌ)

៤- ការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃ ចាប់ពីថ្ងៃទី២ នៃកាលបរិច្ឆេទគ្រោះថ្នាក់

៥- ការផ្ដល់ធនលាភ សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍អស់មួយជីវិត

៦- ការផ្ដល់ធនលាភឧត្តរជីវី ដល់ប្ដី ប្រពន្ធ និងឪពុក ម្ដាយ ឬជនចាស់ជរានៅក្នុងបន្ទុកផ្ទាល់ នៃជនរងគ្រោះ

ASSA ជាអង្គភាពមួយត្រូវបានបង្កើតឡើង តាំងពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ រហូតដល់បច្ចុប្បន្ន មានប្រទេសបណ្ដាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ចំនួន ១០ បានចូលជាសមាជិក ក្នុងនោះមាន ១៨ អង្គភាពសន្តិសុខសង្គម រួមបញ្ចូលទាំងអង្គភាព ប.ស.ស នៃ



បទសម្ភាសរវាងឯកឧត្តមរដ្ឋមន្ត្រីជាមួយអ្នកសារព័ត៌មាន

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈផងដែរ ដែលបានចូលជាសមាជិកកាលពីថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១១។

ប.ស.ស ត្រូវបានចាប់ផ្ដើមអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្ដីពីការងារ នាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្ន ដែលបានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានចំនួន ៧.៥៩៥ សហគ្រាស



ការបទសម្ភាសរវាងអ្នកសារព័ត៌មានជាមួយលោកនាយក ប.ស.ស

និងមានកម្មករនិយោជិតសរុប ១.០៦០.៩៤៧ នាក់។ ក្នុងរយៈពេលជិត ៧ ឆ្នាំមកនេះ សមាជិកដែលទទួល ហានិភ័យការងារ (គ្រោះថ្នាក់ការងារ) គិតជាមធ្យមប្រមាណ ១,៧% នៃសមាជិកសរុប ត្រូវបានចំណាយថវិកាប្រមាណ ៣៦,៦៤៧.៣១៧.៨០០ រៀល។



រូបភាពការទទួលបានវិញ្ញាបនបត្រជាអង្គភាពឆ្នើម ពីប្រធានសមាគមអាស៊ាន

# ពិធីប្រជុំផ្សព្វផ្សាយអប់រំស្តីពីលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ សុវត្ថិភាពចរាចរណ៍ លើមធ្យោបាយដឹកជញ្ជូន និងអត្ថប្រយោជន៍របបសន្តិសុខសង្គម នៅខេត្តកណ្តាល




ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញចូលរួមក្នុងពិធីប្រជុំផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត ស្តីពីលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ, សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមរដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ, ឯកឧត្តមអគ្គនាយកនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកឧកញ៉ា អគ្គនាយកក្រុមហ៊ុន 7NG Group Co.,Ltd នាយកបេឡាជាតិរបប



សិក្ខាកាមចូលរួមក្នុងកិច្ចប្រជុំ

សន្តិសុខសង្គម ក្រុមប្រឹក្សាភិបាល នៃប.ស.ស ក្រុមការងារជំនាញរបស់ ប.ស.ស រួមមាន ទ.ស.ប.ក និង ស.ផ.ក អាជ្ញាធរមានសមត្ថកិច្ចក្នុងតំបន់ និយោជករោងចក្រ សហគ្រាស និងរដ្ឋបាលក្រុមហ៊ុន រដ្ឋបាលរោងចក្រទាំង១៤ និងកម្មករ-កម្មការិនីប្រមាណ ២០០០នាក់ រួមទាំងអ្នកបើកបរប្រចាំនៅរោងចក្រ 7NG Group Co.,Ltd ដែលមានទីតាំងស្ថិតនៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

គោលបំណងនៃការជួបជុំជាមួយបងប្អូនកម្មករនិយោជិតនាថ្ងៃនេះដើម្បីឱ្យបងប្អូនកម្មករបានជួបនិងទទួលនូវមតិសំណេះសំណាលដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួង និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានលើកឡើងថាពិធីប្រជុំនេះធ្វើឡើងក្នុងគោលដៅ ដើម្បីបង្ការហានិភ័យការងារ ឬគ្រោះថ្នាក់ការងារ ដើម្បីឱ្យបងប្អូនកម្មករនិយោជិត ក៏ដូច




ឯកឧត្តមរដ្ឋមន្ត្រី អញ្ជើញថ្លែងសុន្ទរកថា និងផ្តល់អនុសាសន៍ណែនាំក្នុងកិច្ចប្រជុំ



ការអញ្ជើញចូលរួមពីមន្ត្រីថ្នាក់ដឹកនាំក្រោមឱវាទ

ជានិយោជកបានយល់ដឹងពីវិធានការ និងមូលហេតុដើម្បីឈានដល់ការទប់ស្កាត់ និងបង្ការគ្រោះថ្នាក់ការងារ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

ស្របជាមួយគ្នានេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានអំពាវនាវ ដល់កម្មករនិយោជិតអំពីបញ្ហាបន្ថែមម៉ោង ត្រូវហូបអាហារឱ្យបានគ្រប់គ្រាន់ប្រកបដោយអនាម័យមានជីវជាតិនិងសម្រាកឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមានកម្លាំងគ្រប់គ្រាន់ដើម្បីបន្តការងារបានយូរអង្វែង។



ការអញ្ជើញចូលរួមពីមន្ត្រីថ្នាក់ដឹកនាំក្រោមឱវាទ

ទន្ទឹមនឹងនេះ និយោជក ឬតំណាងរោងចក្រត្រូវយកចិត្តទុកដាក់ពីបញ្ហាអនាម័យ សុខភាព សុវត្ថិភាពការងារ ពិសេសនៅកន្លែងធ្វើការរបស់បងប្អូនកម្មករនិយោជិត ដោយធ្វើយ៉ាងណា ឱ្យបរិយាកាសទាំងនៅកន្លែងធ្វើការ និងនៅជុំវិញកន្លែងធ្វើការត្រូវមានខ្យល់អាកាសល្អគ្រប់គ្រាន់ និងគ្មានការសាយភាយ ឬមានក្លិនសារធាតុគីមី ព្រមទាំងធ្វើការណែនាំឱ្យកម្មករនិយោជិត បានយល់ដឹងអំពីអាហាររូបត្ថម្ភផងដែរ។

ជាមួយគ្នានេះ **ឯកឧត្តម** បានលើកឡើងពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដោយឱ្យក្រុមការងារត្រូវសម្របសម្រួល និងលើកទឹកចិត្តដល់រោងចក្រ ដែលមានលទ្ធភាពក្នុងការរៀបចំយន្តការដឹកជញ្ជូនកម្មករនិយោជិត ឱ្យមានកិច្ចសន្យាដឹកជញ្ជូន ដែលធានាសុវត្ថិភាពចរាចរណ៍រវាងរោងចក្រ និងម្ចាស់យានយន្តដឹកកម្មករនិយោជិត ជាពិសេសក្រុមការងារ ត្រូវបន្តសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះបង្រៀនប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករ ឱ្យចូលរួមគោរពច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក និងបន្តបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពីច្បាប់ចរាចរណ៍ និងសុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត។

ក្នុងទិសដៅអនាគត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិការបាននឹងកំពុងរៀបចំដាក់ដំណើរ



លោកនាយក ប.ស.ស ឡើងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំ

ការរបបសន្តិសុខសង្គម ដែលជាជំហានទី២ ផ្នែកថែទាំសុខភាពកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅដើមឆ្នាំ២០១៦ មានន័យថាវាជាយន្តការមួយជួយលើកកម្ពស់សុខភាពកម្មករនិយោជិតនិងជំហានទី៣ដែលគ្រោងរៀបចំដាក់ឱ្យដំណើរការនៅឆ្នាំ២០១៧ គឺផ្នែកប្រាក់សោធន ជាផ្នែកមួយសំខាន់ក្នុងការរួមចំណែកលើកកម្ពស់សិទ្ធិ ចំពោះជនចាស់ជរា ដែលសមិទ្ធិផលរបបសន្តិសុខសង្គមទាំងនេះ គឺជាលទ្ធផលដែលអាចចាត់ទុកថាជាប្រវត្តិសាស្ត្រ នៃការអនុវត្តរបបសន្តិសុខសង្គម។



# កិច្ចប្រជុំ ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិតសារជាថ្មី



កិច្ចប្រជុំពិភាក្សា ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិត

ដើម្បីបម្រើសេវាសាធារណៈជូនដល់បងប្អូនកម្មករនិយោជិត ដែលជាសមាជិក ប.ស.ស ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ប.ស.ស បានកំណត់អត្តសញ្ញាណកម្មករនិយោជិតសាជាថ្មី ទៅតាមប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យា។ ហេតុផលនេះ គឺដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើ ក៏ដូចជាអ្នកទទួលសេវាផងដែរ។

កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៥ នៅសាលប្រជុំបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំប្រជុំ ស្តីពីការកំណត់អត្តសញ្ញាណកម្មករនិយោជិតក្រោមអធិបតីភាព **ឯកឧត្តម សេង សក្ដា** អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម លោក អ៊ុក សមវិទ្យា នាយក ប.ស.ស អស់លោក លោកស្រី ប្រធាន អនុប្រធាននាយកដ្ឋាន រួមទាំងសហជីព និងតំណាងកម្មករនិយោជិតចូលរួមក្នុងកិច្ចប្រជុំនេះ។

កិច្ចប្រជុំនេះធ្វើឡើងក្នុងទិសដៅ ដើម្បីធ្វើការពិភាក្សាទៅលើការកំណត់អត្តសញ្ញាណកម្មករនិយោជិតសាថ្មី ទៅតាមប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យាថ្មី (New Information Technology System) ដើម្បីធ្វើការកំណត់ឱ្យមានភាពជាក់លាក់ និងមានភាពងាយស្រួលក្នុងការបម្រើសេវាសាធារណៈ ជូនដល់បងប្អូនកម្មករនិយោជិត ដែលជាសមាជិកឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ស្របគ្នានេះ ប.ស.ស ក៏ត្រៀមនឹងដាក់ឱ្យដំណើរការផ្នែកធានារ៉ាប់រងសុខភាព ដែលជាជំហានទី២ របស់ខ្លួនក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីផ្នែកធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ដែលជាជំហានទី១។



សិក្ខាកាមចូលរួមមកពីអង្គភាពពាក់ព័ន្ធ តំណាងនិយោជក និងសហជីពមូលដ្ឋាន



# ក្រុមការងារ ស.ផ.គ រៀបចំពិធីប្រជុំផ្សព្វផ្សាយ ស្តីពីការគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដល់កម្មករនិយោជិត និងអ្នកបើកបរ នៅខេត្តស្វាយរៀង



ឯកឧត្តម សេង សក្ដា អញ្ជើញជាអធិបតីក្នុងអង្គពិធី

កាលពីព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ នៅក្រុងបាវិត ខេត្តស្វាយរៀង ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ដឹកនាំ និងអញ្ជើញជាអធិបតីភាពដោយ **ឯកឧត្តម សេង សក្ដា** ប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម រួមដំណើរដោយក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត និងអាជ្ញាធរដែនដីបានអញ្ជើញចុះប្រជុំផ្សព្វផ្សាយ ដល់កម្មករនិយោជិត ជាពិសេសអ្នកបើកបរដឹកកម្មករនិយោជិតផ្ទាល់ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងឱ្យបានខ្ជាប់ខ្ជួនជាបច្ច័យរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យស្ថិតនៅកម្រិតមួយទាបជាអប្បបរមា ដែលអាចធ្វើទៅបាន។

ស្របគ្នានេះ **ឯកឧត្តមប្រធាន** និងក្រុមការងារបានប្រារព្ធពិធីសំណេះសំណាល ដល់អ្នកដែលនៅក្នុងបន្ទុកផ្ទាល់ នៃជនរងគ្រោះ ដោយសារគ្រោះថ្នាក់ចរាចរណ៍រហូតដល់បាត់បង់ជីវិតដែល ប.ស.ស ចាត់ទុកថាជាគ្រោះថ្នាក់ការងារនោះ គឺដើម្បីធ្វើការលើកទឹកចិត្ត និងចូលរួមរំលែកទុក្ខ ក្រោយពីជួបឧបទ្ទវហេតុដ៏រន្ធត់ ដែលសមាជិក ប.ស.ស (កម្មករនិយោជិត) ទទួលរងដោយអកុសលកន្លងមក។

**ឯកឧត្តមប្រធាន** បានធ្វើការអំពាវនាវ ដល់បងប្អូនកម្មករនិយោជិតទាំងអស់ ដែលរៀបការហើយ ឬមិនទាន់បានរៀបការក្តី ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ឱ្យបានត្រឹមត្រូវ ហើយទទួលស្គាល់ជាផ្លូវការ និងដើម្បីឱ្យអ្នកនៅក្នុងបន្ទុកផ្ទាល់របស់ខ្លួនទទួលបានអត្ថប្រយោជន៍ពី ប.ស.ស តាមគោលការណ៍ច្បាប់។ លោកបានជម្រាបជូនផងដែរអំពីបែបបទ និងនីតិវិធីចំពោះការស្នើសុំអត្ថប្រយោជន៍ ក៏ដូចជាសិទ្ធិដែលត្រូវទទួលអត្ថប្រយោជន៍ទៅតាមគោលរបប ឬគោលការណ៍ច្បាប់របស់ ប.ស.ស ជៀសវាងការយល់ច្រឡំ ឬក៏ខកខានមិនទាន់បានទទួលអត្ថប្រយោជន៍ផ្សេងៗទៀតនៅឡើយ។

មួយវិញទៀត **ឯកឧត្តមប្រធាន** បានអំពាវនាវដល់អ្នកដែលនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះ ដែលមិនទាន់ទទួលបានអត្ថ-ប្រយោជន៍ពី ប.ស.ស និងសមាជិក ប.ស.ស ណាដែលពុំទាន់បានទទួលអត្ថប្រយោជន៍ ដូចជាការព្យាបាលឡើងវិញ ដែលមុខរបួសមិនទាន់ជាសះស្បើយនៅឡើយ និងសិទ្ធិទទួលបានអត្ថប្រយោជន៍ដទៃទៀត ត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស ដើម្បីឱ្យ ប.ស.ស ចាត់ចែង និងផ្តល់ជូនសំណងវិញ។



ឯកឧត្តម សេង សក្ដា អញ្ជើញឡើងថ្លែងសុន្ទរកថាក្នុងអង្គពិធី



សិក្ខាកាមដែលជាកម្មករនិយោជិត ចូលរួមក្នុងអង្គពិធី

# កិច្ចប្រជុំផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត ស្តីពីសុវត្ថិភាពចរាចរណ៍ លើមធ្យោបាយដឹកជញ្ជូន សុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត



ឯកឧត្តម សេង សក្កា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

កាលពីព្រឹកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដឹកនាំដោយ **ឯកឧត្តម សេង សក្កា** ប្រធានក្រុមប្រឹក្សាភិបាល នៃ ប.ស.ស និងជាអគ្គនាយក នៃ អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញចូលរួមក្នុងពិធីប្រជុំផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត ស្តីពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនសុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត និងពិធីសំណេះសំណាល ដោយមានការអញ្ជើញចូលរួមពីសមាជិក ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត តំណាងអភិបាលខេត្តសៀមរាប មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប អភិបាលរងស្រុកប្រាសាទបាគង អធិការរងស្រុកប្រាសាទបាគង ប្រធានសាខា



ប.ស.ស ខេត្តសៀមរាប តំណាងក្រុមហ៊ុន ANGKOR PRECISION SYSTEM CO.,LTD និងសមាជិក ប.ស.ស ដែលបានប្រារព្ធធ្វើឡើងនៅក្នុង ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កិច្ចប្រជុំផ្សព្វផ្សាយនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ នៅពេលធ្វើដំណើរពីផ្ទះមកកន្លែងធ្វើការ និងពីកន្លែងធ្វើការមកផ្ទះវិញ។ សម្រាប់អត្ថប្រយោជន៍ដែលផ្តល់ដោយ ប.ស.ស (តាវកាលិក) រួមមាន សេវាសង្គ្រោះបន្ទាន់ ការថែទាំ និងការព្យាបាល ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃតាវកាលិកសម្រាប់អ្នកថែរក្សាជនរងគ្រោះ តាវកាលិកឧត្តរជីវី សម្រាប់អ្នករស់នៅក្នុងបន្ទុកនៃជនរងគ្រោះ ការផ្តល់ប្រាក់វិភាជន៍ និងប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ ប្រាក់សោហ៊ុយសម្រាប់បូជាសព ៤,000,000រៀល និងអត្ថប្រយោជន៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងច្បាប់ជាធរមានត្រូវបានលើកឡើងផងដែរ។ ព្រមទាំងផ្សព្វផ្សាយឱ្យកម្មករនិយោជិតដែលបានរៀបអាពាហ៍ពិពាហ៍រួចទៅធ្វើសំបុត្រអាពាពិពាហ៍នៅឃុំ/សង្កាត់។



លោក ជាវ ប៊ុនរិទ្ធ ឡើងធ្វើបទបង្ហាញក្នុងកិច្ចប្រជុំ

ជាពិសេសការប្រជុំផ្សព្វផ្សាយនេះ ធ្វើឡើងស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបាននឹងកំពុងយកចិត្តទុកដាក់លើសុខទុក្ខ



សិក្ខាកាម ដែលជាកម្មករនិយោជិត ចូលរួមក្នុងកិច្ចប្រជុំ

របស់កម្មករនិយោជិត និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍តាមពាក្យស្លោក "ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍"៕

# សិក្ខាសាលា ស្ដីពីកំណែទម្រង់សន្តិសុខសង្គម ការផ្តល់តាវកាលិក សមស្របសម្រាប់ជនគ្រប់រូប និងការសម្របទៅតាមនិន្នាការចម្បងនៃការងារ



លោក ម៉េង ហុង នាយករង ប.ស.ស ដឹកនាំសហការីចូលរួមសិក្ខាសាលាអន្តរជាតិ

បេឡាជាតិរបបសន្តិសុខសង្គម បានចាត់តាំង លោក ម៉េង ហុង នាយករង ដឹកនាំសហការីចំនួនពីររូប ចូលរួមសិក្ខាសាលាអន្តរជាតិ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីកំណែទម្រង់សន្តិសុខសង្គម ការផ្តល់តាវកាលិកសមស្របសម្រាប់ជនគ្រប់រូប និងការសម្របទៅតាមនិន្នាការចម្បងនៃការងារ ដែលបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Sofitel Nusa Dua Beach Resort កោះបាលីប្រទេសឥណ្ឌូនេស៊ី។ មានសិក្ខាកាមចូលរួមប្រហែល១៥០នាក់ ដែលមកពីបណ្តាប្រទេសអាស៊ាន អាស៊ាន+៣ និងស្ថាប័នពាក់ព័ន្ធ។

គោលបំណង នៃសន្និសីទអន្តរជាតិខាងលើនេះ គឺដើម្បីផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក។ អង្គសិក្ខាសាលាបានធ្វើបទបង្ហាញអំពីកំណែទម្រង់សន្តិសុខសង្គម នៅប្រទេសឥណ្ឌូនេស៊ី ដែលបានលើកឡើងពីប្រព័ន្ធសន្តិសុខសង្គមជាតិ កាលពីមុនរ៉ាប់រងទៅលើផ្នែកឯកជន រួមបញ្ចូលទាំងប្រាក់វិភាជន៍បូជាសព តាវកាលិកហានិភ័យការងារ មូលនិធិបម្រុង និងតាវកាលិកសុខាភិបាល។ បន្ទាប់មកប្រព័ន្ធនេះបានធ្វើការផ្លាស់ប្តូរបន្ថែម ដែលបានរ៉ាប់រងទៅលើកម្មករនិយោជិតទាំងផ្នែកផ្លូវការ រួមមាន(រោងចក្រសហគ្រាស, ក្រុមហ៊ុន, អង្គការ...) និងក្រៅផ្លូវការមាន (អ្នកនេសាទ, កសិករ...) ដោយរួមបញ្ចូលទាំងកម្មករនិយោជិតបរទេស ឱ្យទទួលបាននូវប្រាក់វិភាជន៍សម្រាប់បូជាសព តាវកាលិកហានិភ័យការងារ មូលនិធិបម្រុង និងតាវកាលិកសោធននិវត្តន៍។



ទិដ្ឋភាពរួមនៃអង្គសិក្ខាសាលា

បន្ថែមពីនេះ អង្គសិក្ខាសាលាក៏បានបង្ហាញពីប្រព័ន្ធសន្តិសុខសង្គមជាតិជាទូទៅ: មនុស្ស, ទទួលបានតាវកាលិក និងយុត្តិធម៌សង្គមសម្រាប់ ប្រជាជនឥណ្ឌូនេស៊ី ដើម្បីផ្តល់សន្តិសុខសង្គម រួមមានសាមគ្គីភាព តម្លាភាព គណនេយ្យភាព និងមូលនិធិដ៏គួរឱ្យទុកចិត្តបានដើម្បីបំពេញតម្រូវការជាមូលដ្ឋានសម្រាប់សមាជិក ឬគ្រួសាររបស់ពួកគេបានមួយជីវិត៕



# បេឡាជាតិរបបសន្តិសុខសង្គម បានចាត់មន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្តល់សេវាបុននីតិសម្បទាសម្រាប់កម្មករនិយោជិតពិការ នៅប្រទេសថៃ

ការផ្តល់សេវាបុននីតិសម្បទាសម្រាប់កម្មករនិយោជិតពិការ របស់សមាជិក ប.ស.ស បាននឹងកំពុងអនុវត្តជាបណ្តើរៗ និងត្រូវអនុវត្តពេញលេញនាពេលឆាប់ៗខាងមុខ។

លោក ជៀក លីម៉េង អនុប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិរបបសន្តិសុខសង្គម បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្តល់សេវាបុននីតិសម្បទា




លោក ជៀក លីម៉េង ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការផ្តល់សេវាបុននីតិសម្បទា នៅប្រទេសថៃ



ការចុះទស្សនកិច្ចនៅកន្លែងការងារបច្ចេកទេស

សម្រាប់កម្មករនិយោជិតពិការ រយៈពេល២ សប្តាហ៍ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលផ្តល់សេវាបុននីតិសម្បទា IRC តាមរយៈអង្គភាពសន្តិសុខសង្គម ប្រទេសថៃ SSO។ ការរៀបចំកម្មវិធីបណ្តុះបណ្តាលនេះគឺ ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ ពីការផ្តល់សេវានេះ ដល់សមាគមសន្តិសុខសង្គមអាស៊ាន ASSA និងមានការធ្វើបទបង្ហាញនូវបទពិសោធន៍របស់ប្រទេសថៃ ពីប្រព័ន្ធសន្តិសុខសង្គម និងការផ្តល់សេវាបុននីតិសម្បទាសម្រាប់កម្មករនិយោជិតពិការ។

ប្រព័ន្ធនេះស្ថិតនៅក្រោមការគ្រប់គ្រង ដោយការិយាល័យសន្តិសុខសង្គម SSO ក្រោមក្រសួងការងារប្រទេសថៃ ដែលរួមមានមូលនិធិពីរ គឺមូលនិធិសំណងគ្រោះថ្នាក់ការងារ (Workmen's Compensation Fund) ផ្នែកនេះត្រូវបានផ្តល់ការធានារ៉ាប់រងទៅលើគ្រោះថ្នាក់ និងជំងឺដែលទាក់ទងនឹងការងារ និងមូលនិធិសន្តិសុខសង្គម (Social Security Fund) ផ្តល់ធានារ៉ាប់រងទៅលើជំងឺដែលមិនទាក់ទងនឹងការងារ, ទុព្វលភាព, មរណៈភាព, មាតុភាព, ជរាភាព, វិភាជន៍សម្រាប់កុមារ និងនិកម្មភាព។



រូបភាពការប្រគល់វត្ថុអនុស្សាវរីយ៍



ការថតរូបអនុស្សាវរីយ៍

វគ្គនេះដែរមានការចូលរួមពីមន្ត្រី SSO និងIRC នៅថ្នាក់កណ្តាល និងតាមខេត្ត ព្រមទាំងសមាជិក ASSA ០៥ប្រទេសមានអ្នកចូលរួមចំនួន ០៦ នាក់មកពីប្រទេសកម្ពុជា, ប្រទេសឡាវ, ប្រទេសសឹង្ហបុរី, ប្រទេស ម៉ាឡេស៊ី និងប្រទេសវៀតណាម៕

# កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹង សេវាផ្តល់ តាវកាលិកហានិភ័យការងារ

ដើម្បីពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូន ដល់បងប្អូនកម្មករនិយោជិតឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ទើបនៅក្នុងខែមិថុនា ឆ្នាំ២០១៥កន្លងមកនេះ បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារ នៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន ចំនួន០៣។



បទបង្ហាញ ស្តីពីការពង្រឹងសេវាការផ្តល់តាវកាលិកហានិភ័យការងារ

កិច្ចប្រជុំធ្វើឡើងក្រោមការដឹកនាំដោយ លោក ម៉េង ហុង នាយករង ប.ស.ស ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានមន្ត្រី និងបុគ្គលិកសាខា ប.ស.ស ខេត្ត ព្រមទាំងមានការចូលរួមពីលោក លោកស្រី ជានិយោជក នាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន ជាច្រើនរូបទៀត។

លោកនាយករង ប.ស.ស ក៏បានលើកបញ្ជាក់ពីគោលបំណងនៃកិច្ចប្រជុំនេះផ្តោតសំខាន់ ទៅលើការពង្រឹងសេវារបស់មន្ទីរពេទ្យ សេវារបស់ធនាគារអេស៊ីលីដាភីអិលស៊ី សេវាសាខា ប.ស.ស ខេត្ត រួមមានទាំងបទបង្ហាញ ស្តីពីការចុះបញ្ជិកា ការប្រមូលភាគទាន ការចុះអធិការកិច្ច ការអង្កេតគ្រោះថ្នាក់ និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗទៀតដូចមានចែង ក្នុងច្បាប់ជាធរមានក្នុងន័យបង្កើនការ យល់ដឹងក្នុងការអនុវត្ត និងសិទ្ធិក្នុងការទទួលបានតាវកាលិក។ ផ្នែកនេះដែរក៏ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីក្នុងការដោះស្រាយបញ្ហារួមគ្នាដើម្បីអភិវឌ្ឍកិច្ចដំណើរការប្រព្រឹត្តទៅរបស់ ប.ស.ស ឱ្យកាន់តែល្អ និងមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។





លោក ម៉េង ហុង នាយករង ប.ស.ស អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

ជាចុងក្រោយមុននឹងបញ្ចប់កិច្ចប្រជុំ លោក ម៉េង ហុង បានមានមតិផ្តាំផ្ញើ ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន រាល់ពេលមានបញ្ហាដែលទាក់ទងនឹងគ្រោះថ្នាក់ការងារកើតឡើង សូមទាក់ទងមកកាន់ស្នាក់ការ ប.ស.ស ឬអាចធ្វើការរាយការណ៍មកកាន់ស្នាក់ការកណ្តាលតាមរយៈលេខទូរស័ព្ទ ១២៨៦ ដោយឥតគិតថ្លៃ។



សិក្ខាកាមជាតំណាងរោងចក្រ សហគ្រាស់ និងសមាជិកមូលដ្ឋានចូលរួមក្នុងកិច្ចប្រជុំ

លោកក៏បានសំណូមពរឱ្យសហគ្រាស គ្រឹះស្ថាន ធ្វើការប្រកាសចំនួនកម្មករ និងការបង់ភាគទានឱ្យបានត្រឹមត្រូវជៀសវាងមានពិន័យពី ប.ស.ស។

# ក្រុមការងារ ស.ផ.ក បានចុះផ្សព្វផ្សាយអប់រំ ណែនាំ ដល់អ្នកបើកបរ ដឹកកម្មករ និយោជិត តាមបណ្តាសហគ្រាស គ្រឹះស្ថាន ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក



លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

ដោយទទួលបានគោលការណ៍ពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសុំសិទ្ធិក្នុងការរៀបចំប្រឡង និងផ្តល់ប័ណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋាន រោងចក្រ សហគ្រាស ដោយអនុវត្តតាមនីតិវិធី នៃការបណ្តុះបណ្តាលប្រឡង និងផ្តល់ប័ណ្ណបើកបរ ដែលមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្តចូលរួមសហការជាមួយក្រុមការងារ (ស.ផ.ក) ក្នុងការអនុវត្តផ្ទាល់នៅតាមបណ្តារោងចក្រ សហគ្រាសនានា។

ហេតុផលនេះហើយ ទើបរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអង្គភាពបេឡាជាតិរបបសន្តិសុខសង្គមបានយកចិត្តទុកដាក់រិះរកគ្រប់មធ្យោបាយ និងបង្កើតឱ្យមានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់



លោក យាម យុទ្ធា ធ្វើបទបង្ហាញអំពីអត្ថប្រយោជន៍ ប.ស.ស



ពិធីផ្តល់មួកសុវត្ថិភាពជូនសិក្ខាកាម

គាំពារកម្មករនិយោជិត ដើម្បីធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរនៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន និងអ្នកបើកបរដឹកកម្មករនិយោជិតទាំងអស់ ឱ្យបានយល់ដឹងពីច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ដែលកើតមានឡើងជាយថាហេតុ ឱ្យនៅកម្រិតមួយទាប ជាអប្បបរមា ដែលអាច



ការធ្វើបទបង្ហាញ ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក

ធ្វើទៅបាន។

ជាក់ស្តែង នៅចុងឆ្នាំ២០១៥ កន្លងមកនេះ ក្រុមការងារ ស.ផ.ក បានចុះផ្សព្វផ្សាយតាមបណ្តារោងចក្រ សហគ្រាសមួយចំនួន ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ក្នុងនោះក្រុមការងារបានធ្វើបទបង្ហាញ និងធ្វើការណែនាំ និងជំរុញឱ្យអ្នកបើកបរទាំងអស់ ត្រូវទៅរៀននៅសាលាបង្រៀនបើកបរឱ្យបានត្រឹមត្រូវ ប្រឡងយកប័ណ្ណបើកបរ ត្រូវមានការយល់ដឹងពីច្បាប់ចរាចរណ៍ និងត្រួតពិនិត្យយានយន្តជាប្រចាំរៀងរាល់ថ្ងៃមុនពេលចេញដំណើរ។ ចំពោះបងប្អូនកម្មករ-កម្មការិនី ត្រូវគោរពច្បាប់ចរាចរណ៍ ត្រូវពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ ដើម្បីការពារអាយុជីវិតរបស់ខ្លួនផងដែរ៕

# កម្មករ-កម្មការិនីប្រមាណ ៤៤នាក់សន្លប់នៅក្រុមហ៊ុនសេរី (ខេមបូឌា) ខូអិលធីឌី ខេត្តកំពង់ស្ពឺ បណ្ដាលមកពីក្រុមហ៊ុនបាញ់ថ្នាំសម្លាប់សត្វល្អិត



រូបភាពជនរងគ្រោះសម្រាកព្យាបាលនៅមន្ទីរពេទ្យ

ដើម្បីរួមចំណែកក្នុងការកាត់បន្ថយករណីសន្លប់ ដែលកើតមានចំពោះបងប្អូនកម្មករនិយោជិត ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានជំរុញឱ្យក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត បង្កើនការអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់និយោជក និងធ្វើការចុះស្រាវជ្រាវពិនិត្យរកមូលហេតុសន្លប់, ចាត់វិធានការសង្គ្រោះបន្ទាន់ និងរកវិធីក្នុងការទប់ស្កាត់ករណីសន្លប់របស់កម្មករនិយោជិតកើតមាននៅកន្លែងធ្វើការ, សហការជាមួយ មន្ទីរពហុព្យាបាលដើម្បីបង្កើតរូបមន្តព្យាបាលសន្លប់ និងកំណត់ពីតម្លៃព្យាបាល, សហការជាមួយស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីដឹកបញ្ជូនជនរងគ្រោះ ទៅមន្ទីរពហុព្យាបាលប្រកបដោយសុវត្ថិភាព បានទាន់ពេលវេលា ជាពិសេសធ្វើការណែនាំ និងផ្សព្វផ្សាយកម្មវិធីបង្ការគ្រោះថ្នាក់ ដល់និយោជកឱ្យយល់ដឹង និងអនុវត្តតាម។

ជាក់ស្ដែងកាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ មានករណីកម្មករ-កម្មការិនីនៅក្រុមហ៊ុនសេរី (ខេមបូឌា) ខូអិលធីឌី មានទីតាំងស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៤ភូមិចំបក់ ឃុំវល្លិ៍ស ស្រុកសំរោងទង បានសន្លប់៤៤នាក់ (ស្រីទាំងអស់) ក្នុងចំណោមកម្មករសរុបចំនួន ៧០០នាក់ ប្រុស៦០នាក់ ហើយមូលហេតុបឋម អាចបណ្ដាលមកពីក្រុមហ៊ុនបានបាញ់ថ្នាំសត្វល្អិត កាលពីយប់ថ្ងៃទី០៦ ខែធ្នូ ហើយព្រឹកឡើងមិនបានបើកកង្ហារបឺតខ្យល់ចេញ នៅពេលកម្មករចូលធ្វើការ



ក៏មានកម្មករសន្លប់តែម្ដង ព្រមទាំងបានសន្លប់តៗគ្នា រហូតដល់ច្រើននាក់ នេះបើយោងតាមមន្ត្រីសាខា ប.ស.ស ខេត្ត ថ្លែងប្រាប់ឱ្យដឹងយ៉ាងដូច្នេះ។

រហូតមកដល់ពេលនេះមន្ត្រីសាខា ប.ស.ស ខេត្តសហការជាមួយរដ្ឋបាលរោងចក្រ បានបញ្ជូនជនរងគ្រោះទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ១៤នាក់ និងគ្លីនិកសុខណា៣០នាក់។ ចំពោះការចំណាយលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាលជនរងគ្រោះ រហូតជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣

## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

### ផ្នែកទី ១

### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

